# មេរៀនទី ៧៩៖ ជនជាតិអ៊ីស្រាអែលឆ្លងកាត់សមុទ្រក្រហម

## និក្ខមនំ ១៣៖១៧ -១៤៖៣១

**មេរៀន** *( យូធូបលីង )*៖ https://youtu.be/BzCDBHX4ACQ

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/78fb3nX8eqM

**គោលចំណាំង៖** គ្មានអ្វីដែលព្រះធ្វើមិនបាននោះទេ

**ខគម្ពីរចងចាំ៖ ទំនុកដំកើង ២៣៖៤** *"អើ ទោះបើទូលបង្គំដើរកាត់ច្រកភ្នំនៃម្លប់សេចក្ដីស្លាប់ក៏ដោយ គង់តែមិនខ្លាចសេចក្ដីអាក្រក់ណាឡើយ ដ្បិតទ្រង់គង់នៅជាមួយនឹងទូលបង្គំ"។*

**ចំរៀង** *( យូធូបលីង )*៖

១. ខ្ញុំសប្បាយរីករាយ https://youtu.be/2LWPsq-KZvo

២. ព្រះអង្គទ្រង់អស្ចារ្យ https://youtu.be/QXEVqO94wpg

៣. បើទ្រង់គង់ជាមួយ https://youtu.be/2CzIW4_ueg0

### ១.អធិស្ឋាន

### ២.ចំរៀង *សូមច្រៀងចំរៀងដែលមាននៅក្នុងយូធូបលីងខាងលើ*

### ៣. ល្បែងកំសាន្ត *« ពត់មេដៃ »*

តោះនាំគ្នាលេងល្បែងចំបាប់មេដៃជាមួយដៃគូរបស់ប្អូន (ដើម្បីយកឈ្នះក្នុងល្បែងនេះប្អូនត្រូវសង្កត់មេដៃរបស់គូប្រកួតរបស់ប្អូនឲ្យជាប់)។ ហើយអ្នកដែលឈ្នះត្រូវទៅប្រកួតជាមួយអ្នកដែលឈ្នះផ្សេងទៀត។ នៅពេលដែលមានអ្នកឈ្នះតែម្នាក់ អ្នកដែលឈ្នះនោះនឹងឡើងទៅ ប្រកួតជាមួយនឹងគ្រូ។ ដោយសារតែគ្រូ



ជាមនុស្សពេញវ័យ ដូច្នេះគ្រូអាចយកឈ្នះល្បែងនេះបានដោយងាយស្រួល។ ទោះបីជាអ្នកខ្លាំងជាងក្មេងម្នាក់ឬ ពីរនាក់ក៏ដោយ ក៏នៅមានអ្នកផ្សេងខ្លាំងជាងអ្នកដែរ។ ប៉ុន្តែគ្មាន អ្វីដែលខ្លាំងជាង ព្រះនោះទេ! ព្រះជាម្ចាស់ជាព្រះដែលខ្លាំង និងមានអំណាចបំផុត! ហើយជាការពិត សម្រាប់ព្រះគ្មានអ្វីដែលថាទ្រង់មិនអាចធ្វើបាននោះទេ!

### ៤. ការណែនាំមេរៀន

ពួកយើងធ្លាប់បានរៀនរួចមកហើយអំពីជនជាតិអ៊ីស្រាអែល និង ពីវិធីដែលព្រះជួយរំដោះពួកគេ។ បន្ទាប់ពីពួកគេចាកចេញពីអេហ្ស៊ីបពួកគេមិនដឹងថា តើពួកគេត្រូវទៅទីណានោះទេ! ពួកគេបានដើរវិលវល់នៅកណ្ដាលទីរហោស្ថាន។ នៅវាលរហោស្ថាន បើពេលថ្ងៃគឺក្ដៅខ្លាំង បើពេលយប់គឺត្រជាក់ខ្លាំង តើជនជាតិអ៊ីស្រាអែលរាប់លាននាក់អាចរស់បានយ៉ាងដូចម្ដេចនៅក្នុងទីរហោស្ថាន? យើងបានដឹងហើយថា គ្មានអ្វីដែលព្រះរបស់យើងមិនអាចធ្វើបាននោះទេ!

### ៥. រឿងនៅក្នុងព្រះគម្ពីរ

បន្ទាប់ពីព្រះអង្គបានរំដោះរាស្ត្ររបស់ទ្រង់ពីអេហ្ស៊ីបហើយ ទ្រង់បាននាំពួកគេទៅរស់នៅកន្លែងថ្មីមួយ។ ដោយនៅពេលថ្ងៃ ព្រះអង្គបានប្រើបង្គោលពពកដើម្បីបង្ហាញផ្លូវពួកគេថាត្រូវទៅណា។ បង្គោលពពក

អណ្តែតឡើង ខ្ពស់នៅលើមេឃដើម្បីឲ្យមនុស្សទាំងអស់បានមើលឃើញ។ នៅពេលដែលពួកគេដើរតាមពពកនោះពួកគេដឹងថា ពួកគេកំពុងតែដើរផ្លូវដែលត្រឹមត្រូវ។ លើសពីនេះទៅទៀត ពពកបានជួយការពារកម្តៅថ្ងៃឲ្យពួកគេផងដែរ។ ទោះយ៉ាងណាក្តី នៅពេលយប់ពួកគេមិនអាចមើលឃើញបង្គោលពពកទេ។ នៅពេលមេឃចាប់ផ្តើមងងឹត, បង្គោលពពកក៏ចាប់ផ្តើមក្លាយជាបង្គោលភ្លើងដែរ។ ពួកគេអាចមើលឃើញភ្លើងនៅពេលមេឃងងឹត ហើយវាក៏ជួយឲ្យពួកគេមានភាពកក់ក្តៅផងដែរ។

ថ្ងៃមួយ ព្រះបានដឹកនាំរាស្ត្ររបស់ទ្រង់ទៅកាន់សមុទ្រក្រហម ដែលមានទឹកជ្រៅ ហើយធំល្វឹងល្វើយ។ ប្រជាជនមានការភ័យខ្លាច ដោយព្រោះផារ៉ោនបានផ្លាស់ប្តូរគំនិតរបស់គាត់ពីការដែលបានអនុញ្ញាតឱ្យជនជាតិអ៊ីស្រាអែលចាកចេញពីអេហ្ស៊ីប - កងទ័ពរបស់ផារ៉ោនកំពុងតែដេញតាមពួកគេ! ពួកគេនឹងត្រូវឆ្លងកាត់សមុទ្រក្រហមដើម្បីរត់គេចពីកងទ័ពទាំងនោះ។ ព្រះជាម្ចាស់បានធ្វើរឿងដ៏អស្ចារ្យមួយនៅថ្ងៃនោះគឺខ្លាំងជាងការដែលទ្រង់ធ្វើឲ្យមានបង្គោលពពកឬបង្គោលភ្លើង! «បន្ទាប់មកម៉ូសេបានលាតដៃរបស់គាត់នៅមាត់សមុទ្រ ហើយនៅពេញមួយយប់នោះព្រះអម្ចាស់បានញែកទឹកសមុទ្រឲ្យហូរបញ្ច្រាសវិញ ដោយឲ្យខ្យល់បក់ពីទិសខាងកើតហើយប្រែក្លាយទៅជាដីហួតហែង។ ទឹកត្រូវបានញែកចេញ ហើយជនជាតិអ៊ីស្រាអែលបានឆ្លងកាត់សមុទ្រនៅលើដីស្ងួតដោយមានជញ្ជាំងទឹកនៅខាងស្តាំនិងខាងឆ្វេងរបស់ពួកគេ ” **និក្ខមនំ ១៤:២១-២២** សំរាប់ព្រះគ្មានអ្វីដែលទ្រង់ធ្វើមិនបានទេ!

ព្រះបានធ្វើឱ្យពពកផ្លាស់ទីដើម្បីបង្ហាញនូវកន្លែងដែលព្រះចង់ឱ្យពួកគេទៅ ហើយការពារកម្តៅឲ្យពួកគេ។ ព្រះបានធ្វើឱ្យភ្លើងផ្លាស់ទីដើម្បីបង្ហាញនូវកន្លែងដែលព្រះចង់ឱ្យពួកគេទៅហើយធ្វើឱ្យពួកគេកក់ក្តៅ។ ព្រះបានទប់ទឹកមិនឲ្យហូរ ហើយឲ្យហូរបញ្ច្រាសឡើងវិញដើម្បីធ្វើឱ្យដីស្ងួតសម្រាប់ជនជាតិអ៊ីស្រាអែល ធ្វើដំណើរឆ្លងកាត់។ ព្រះយេហូវ៉ា ទ្រង់មានព្រះបន្ទូលនឹងម៉ូសេថា ចូរឯងលើកដៃទៅលើសមុទ្រទៅ ដើម្បីឲ្យទឹកបានហូរត្រឡប់គ្របទៅលើពួកសាសន៍អេហ្ស៊ីប ព្រមទាំងរទេះ និងពួកទ័ពសេះគេផង នោះម៉ូសេក៏លើកដៃទៅលើសមុទ្រ ហើយដល់ព្រឹកឡើង ទឹកក៏ហូរប្រសព្វចូលទៅនៅកន្លែងធម្មតាវិញ ពួកសាសន៍អេហ្ស៊ីបក៏នាំគ្នារត់ចេញពីទឹក ប៉ុន្តែព្រះយេហូវ៉ាទ្រង់ផ្តួលគេនៅកណ្តាលសមុទ្រទៅ ហើយទឹកក៏ត្រឡប់មកគ្របលើអស់ទាំងរទេះ និងពួកពលសេះ ហើយនឹងពលទ័ពផារ៉ោនទាំងអស់ ដែលបានចូលទៅក្នុងសមុទ្រតាមពួកកូនចៅអ៊ីស្រាអែល គ្មានរួចអ្នកណាមួយសោះឡើយ។ គ្មានអ្វីដែលខ្លាំងដូចព្រះដ៏មានមហិទ្ធិរបស់យើងទេ!

## ៦. សំនួរពិភាក្សា

១. តើព្រះបានប្រើអ្វីនៅពេលថ្ងៃដើម្បីដឹកនាំផ្លូវសម្រាប់ជនជាតិអ៊ីស្រាអែល? (*បង្គោលពពក*)

២. តើព្រះបានប្រើអ្វីនៅពេលយប់ដើម្បីដឹកនាំផ្លូវសម្រាប់ជនជាតិអ៊ីស្រាអែល? (*បង្គោលភ្លើង*)

៣. តើព្រះបានជួយជនជាតិអ៊ីស្រាអែលដោយរបៀបណា នៅពេលដែលកងទ័ពអេហ្ស៊ីបកំពុងតែដេញតាមចាប់ពួកគេ? (*ព្រះបានដាក់ឲ្យមានភាពងងឹតនៅខណ្ឌកណ្តាលរវាងជនជាតិអ៊ីស្រា-អែល និង ទ័ពអេហ្ស៊ីប។ បន្ទាប់មក ព្រះអង្គបានញែក សមុទ្រក្រហមដើម្បីឱ្យជនជាតិអ៊ីស្រាអែលឆ្លងទៅត្រើយម្ខាងទៀត*)

៤. តើមានការអ្វីដែលព្រះមិនអាចធ្វើបានដែរឬទេ? (*គ្មានទេ*)
តើព្រះបានធ្វើការអ្វីខ្លះសំរាប់ប្អូនកន្លងមក? (*ផ្តល់កម្លាំង ប្រាជ្ញា អំណាចដើម្បីធ្វើការជ្រើសរើសអ្វីមួយឲ្យបានត្រឹមត្រូវ ព្យាបាលជំងឺ។ ល។* )

## ៧. ខគម្ពីរចងចាំ

**ទំនុកដំកើង ២៣៖៤** *“អើ ទោះបើទូលបង្គំដើរកាត់ច្រកភ្នំនៃម្លប់សេចក្ដីស្លាប់ក៏ដោយ គង់តែមិនខ្លាចសេចក្តីអាក្រក់ណាឡើយ ដ្បិតទ្រង់គង់នៅជាមួយនឹងទូលបង្គំ។”*

- ដើម្បីជួយកុមារឱ្យចងចាំខគម្ពីរនេះដោយប្រើកាយវិការៈ
    - ទោះបើទូលបង្គំ *(ប្រើមេដៃចង្អុលដាក់លើដើមទ្រូង)*
    - ហើយកាត់ច្រក ជ្រលង *(ប្រើដៃទាំងពីរផ្តុំចូលគញ្ញនាធ្វើដូចជាទឹករលក)*
    - ភ្នំ *(ដាក់ដៃទាំងពីរផ្តុំ ឡើងលើដូចសំពះ)*
    - នៃសេចក្តីស្លាប់ *(ដាក់ដៃទាំង២ទ្រក្បាលផ្អៀងងាកទៅខាងឆ្វេងឬស្តាំ)*
    - ទូលបង្គំ *(ប្រើមេដៃចង្អុលដាក់លើដើមទ្រូង)*
    - មិនខ្លាចសេចក្តីស្លាប់ *(លើកដៃទាំងពីររាខ្វែងគ្នា)*
    - ត្បិតព្រះទ្រង់គង់ជាមួយទូលបង្គំ *(លើកចង្អុលដៃទាំងពីរហើយលើកមេដៃទាំងពីរមកដាក់លើដើមទ្រូង)*
    - ព្រនង់ និងដំបងរបស់ព្រះអង្គកម្សាន្តចិត្តទូលបង្គំ *(ក្តាប់ដៃខាងស្តាំ ហើយខាងឆ្វេងលើកឡើង ហើយលាតដៃទាំងពីរហើយខ្វែងនៅលើដើមទ្រូង)*

**៨. ហត្ថកម្ម**

| | |
|---|---|
|  ១.បត់ក្រដាស A4 ពណ៌ខៀវជាពីរ (បត់បណ្តោយ) ហើយកាត់ជាពីរ<br>២.កាត់ផ្នែកចំហៀងនៃក្រដាសប្រវែងប្រហែលជា ២ ឬ ៣ សង់ទីម៉ែត្រពីគ្នា (កុំកាត់ផ្តាច់) |  ៣.បិទក្រដាសទាំង ២ ចំហៀងនៅ លើក្រដាសមួយផ្ទាំងផ្សេងទៀត ដាក់ផ្នែកដែលកាត់ នោះបែរចេញក្រៅ និងទុកឲ្យមានប្រលោះនៅកណ្តាល រួចមូរបំនែកដែលកាត់តូចៗ នោះអោយរមូរតិចៗ |
|  ៤. កាត់យករូបមនុស្សចេញមក (សូមកុំភ្លេចទុកឲ្យសល់គែមនៅ ខាងក្រោមដើម្បីបិតការ)ហើយផាត់ពណ៌រូបភាពទាំងនោះ *(រូបមនុស្សនៅទំព័រខាងក្រោម)* | |
|  ៥. បិតរូបជនជាតិអ៊ីស្រាអែលកំពុងឆ្លងកាត់សមុទ្រក្រហម | |

**៩. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១០.អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូៈ** (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)
យើងរស់នៅក្នុងគ្រាលំបាក ហើយវាមិនងាយស្រួលទេសំរាប់មនុស្សដែលខូចចិត្ត និងមានអារម្មណ៍អស់សង្ឃឹម ឬមានអាម្មណ៍វង្វេងវង្វាន់។ តែទំនាក់ទំនងជាមួយព្រះយេស៊ូវអាចផ្តល់ឲ្យយើងមានសេចក្តីសុខសាន្ត និងក្តីអំណរ។ ព្រះយេស៊ូវជាពន្លឺនៅក្នុងភាពងងឹត។ តើពេលនេះមានអ្វីនៅក្នុង ជីវិតអ្នកដែល ព្រះអង្គនឹងលូកព្រះហស្តទ្រង់មកជួយអ្នកបាន? តើអ្នកអាចធ្វើអ្វីបានដើម្បី ភ្ជាប់ទំនាក់ទំនងជាមួយព្រះ ក្នុងកំឡុងពេលភ័យខ្លាច និងអស់សង្ឃឹម។ សម្រាប់សប្តាហ៍នេះសូមប្រើពេល ២ឬ៣ នាទីស្ងៀមស្ងាត់តែម្នាក់ឯងរៀងរាល់ថ្ងៃ ដោយគ្មានក្មេងមករំខាន គ្មានទូរទស្សន៍ គ្មានតន្ត្រី។ សូមដាក់កិច្ចការទាំងអស់នៅក្នុងព្រះហស្តរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់អ្នក។

# ជនជាតិអ៊ីស្រាអែលឆ្លងកាត់សមុទ្រក្រហម

